# ភ្នំពេញ – មណ្ឌលគិរី (៣ថ្ងៃ ២យប់)

## ថ្ងៃទី១ : ភ្នំពេញ_មណ្ឌលគិរី(អាហារ ៣ពេល)



ម៉ោង០៥:០០ព្រឹកចេញដំណើរពីភ្នំពេញឆ្ពោះទៅកាន់ខេត្តមណ្ឌលគិរី ដោយរថយន្តទេសចរណ៍ទំនើបម៉ាស៊ីនត្រជាក់។ ទស្សនាទិដ្ឋភាពធម្មជាតិតាមដងផ្លូវ បន្ទាប់ពីទទួលទានអាហារថ្ងៃត្រង់ នៅស្រុក ស្នួល ខេត្តក្រចេះបន្តដំណើរទៅទស្សនាចំការស្រល់និង ជ្រោះរមនាទី២នាខេត្តមណ្ឌលគិរីរួចបន្តដំណើរទៅកាន់ទីរួមខេត្ត ដើម្បីទទួលទានអាហារពេលល្ងាច និងសំរាក។

## ថ្ងៃទី២ : ទឹកជ្រោះប៊ូស្រា_ភ្នំដោះក្រមុំ(អាហារ ៣ពេល)



បន្ទាប់ពីទទួលទានអាហារពេលព្រឹករួច ចេញដំណើរទៅទស្សនាព្រមទាំងងូតទឹកកំសាន្តនៅ ជ្រោះប៊ូស្រា និងទស្សនា ជ្រោះអូរប្លាយ។ ត្រលប់មកទទួលទានអាហារថ្ងៃត្រង់នៅទីរួមខេត្ត។ បន្ទាប់ពីអាហារថ្ងៃត្រង់រួចបន្តដំណើរទៅទស្សនា និង ស្រូបយកខ្យល់ធម្មជាតិនៃជំនោរមណ្ឌលគិរីនាកំពូលភ្នំដោះក្រមុំ រួចហួសទៅទស្សនាសមុទ្រភ្នំ និងភ្នំប្រាយឆៅ។ ត្រលប់មកទស្សនា ទឹកធ្លាក់សែនមនោរម្យ រួចហួសទៅទស្សនា ភូមិជនជាតិភាគតិចព្នៃកាជនជាតិព្នង។ ត្រលប់មកទទួលទានអាហារពេលល្ងាចនៅក្នុងសួនច្បារក្រោមពន្លឺចន្ទ្រ ដ៏ស្រទន់ នាទីរួមខេត្តនារាត្រីនោះមានរៀបចំកម្មវិធីរាំលេងកំសាន្តនិងច្រៀងខារ៉ាអូខេរហូតដល់ម៉ោង១០យប់ទើបសំរាក។ព្រមទាំងមានកម្មវិធី កំសាន្តសប្បាយជាមួយនឹងការចាប់រង្វាន់ជាច្រើនទៀតផង ។

## ថ្ងៃទី៣ : មណ្ឌលគិរី_ភ្នំពេញ (អាហារ ២ពេល)



ក្រោយពីស្រស់ស្រូបអាហារពេលព្រឹករួចចេញដំណើរទៅទស្សនាផ្សារមណ្ឌលគិរីរួចបន្តទៅទស្សនានិងភ្លក់រសជាតិស្រាបឺតនៅរមណីយ៍ដ្ឋានអូររមីសមុននឹងចេញដំណើរត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ ដោយពាំនាំមកជាមួយនូវអារម្មណ៍ភ្លឺថ្លានិងភាពសប្បាយរីករាយជាមួយនឹង ទិដ្ឋភាពដ៏ស្រស់ត្រកាលនៃខេត្តមណ្ឌលគិរី។

**ដំណើរកំសាន្តរួមមាន :**

☞មធ្យោបាយធ្វើដំណើរដោយរថយន្តទេសចរណ៍ទំនើបមានម៉ាស៊ីនត្រជាក់
☞បន្ទប់ស្នាក់នៅរួមសំរាប់គ្នា ២នាក់ក្នុងមួយបន្ទប់ ។ សណ្ឋាគារផ្កាយ
☞សំបុត្រចូលទស្សនា
☞អាហារតាមកម្មវិធី១ថ្ងៃ៣ពេលនិងទឹកបរិសុទ្ធ
☞សេវាកម្មពីមគ្គុទ្ទេសក៍ទេសចរណ៍
☞វត្ថុអនុស្សាវរីយ៍ពី ក្រុមហ៊ុន អេស៊ាអិចផ្លរ៉ើទេសចរណ

**បញ្ជាក់:**

☞ចេញដំណើររាល់ថ្ងៃសុក្រ និងថ្ងៃបុណ្យជាតិផ្សេង និងទៅតាមតំរូវការចំពោះក្រុមដែលមានគ្នា ចាប់ពី១០នាក់ឡើង។
☞ក្មេងក្រោមអាយុ១២ឆ្នាំ ស្នាក់នៅជាមួយឪពុកម្តាយតំលៃ ៧៥% នៃមនុស្សពេញវ័យ
☞សំរាប់ការស្នាក់នៅបន្ទប់មួយម្នាក់ឯងត្រូវបង់បន្ថែម ១៥ ដុល្លាអាមេរិក
☞សូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់

**ព័ត៌មានលំអិតសូមអញ្ជើញទំនាក់ទំនង**

ទូរស័ព្ទលេខ: ០២៣ ២១៨ ៦០៩
អ៊ីមែល: book@asiaexplorertravel.com